【កំណៃផ្នាំ2025】

# ឧទាហរណ៍ល្អប្រសើរនៃការទទួលជនបរទេសជំនាញជាក់លាក់សម្រាប់វិស័យកសិកម្ម

## ក្រុមហ៊ុន JAPAN vegetables Co., Ltd. (ក្រុមហ៊ុន Nihon Agri, Inc.)

## ~ ពង្រីកអាជីវកម្មនាំចេញដំឡូងផ្វា និងមានអ្នកដឹកនាំក្រុមផលិត ជាជនបរទេស ~

<table>
<tr>
<td>ព័ត៌មានមូលដ្ឋាន<br>ទីតាំង៖ ក្រុងកាកេហ្គាវ៉ា ខេត្តស៊ិហ្សឹអូកា<br>ក្រុមហ៊ុនមេ (ក្រុមហ៊ុន Nihon Agri, Inc.)<br>ផ្ទៃក្រឡាដាំដុះ៖ ដីវាលចំនួន6ហិកតា<br>ផ្ទះដំណាំចំនួន2ខ្នង<br>ដំណាំសំខាន់៖ ដំឡូងផ្វា<br>សមាសភាពបុគ្គលិក៖ ជនជាតិជប៉ុន 28 នាក់ + ជនបរទេស 6 នាក់ (ជនជាតិឥណ្ឌូនេស៊ីទាំងអស់)<br>ជំនាញជាក់លាក់កម្រិត2៖ 2 នាក់</td>
<td></td>
</tr>
<tr>
<td colspan="2">កិច្ចផ្តួចផ្តើមពិសេសដោយឡែក (ការរីកចម្រើនក្នុងអាជីព និង កិច្ចគាំទ្រដល់ការបង្កើនសមត្ថភាព)<br>① យើងបង្ហាញផ្លូវសម្រាប់ការឡើងតំណែងជាអ្នកដឹកនាំនីមួយៗ ដោយមិនគិតថាជាជនជាតិជប៉ុន ឬជនបរទេសទេ។<br>អ្នកដឹកនាំក្រុមផលិតនៅពេលបច្ចុប្បន្ននេះ គឺជាជនបរទេស ហើយគាត់គឺជាអ្នករៀបចំ</td>
</tr>
</table>

| |
|---|
| ផែនការផលិតប្រចាំឆ្នាំ និងគ្រប់គ្រងវឌ្ឍនភាពការងារ ព្រមទាំងចុះទៅសង្កេតអ្នកបំពេញការងារកសិកម្មនៅដីផលិតខ្នាតធំផងដែរ។<br>② ក្រុមហ៊ុន ឧបត្ថម្ភថ្លៃពេញ 100% សម្រាប់ការយកបណ្ណបើកបររថយន្ត គ្រឿងចក្រធុនធ្ងន់ និងហ្វកលីហ្វ ជាដើម។ |
| 【ចូលខ្លួនមកថ្មី និងពង្រីកអាជីវកម្មនាំចេញដំឡូងជ្វា】<br>① ក្រុមហ៊ុនមេ ធ្វើការនាំចេញផ្លែប៉ោម និងមានជំនាញនៃការនាំចេញ។ ហេតុនេះហើយយើងក៏បានចូលខ្លួនមកថ្មីក្នុងខេត្តស៊ិហ្សូអូកា ដែលជាទីកន្លែងផលិត និងនាំចេញដំឡូងជ្វាដែលពេញនិយមក្នុងតំបន់អាស៊ី។ ខណៈពេលជួបការលំបាកក្នុងការរកបានធនធានមនុស្ស យើងបានឮថា អ្នកនៅក្នុងមូលដ្ឋានរបស់យើងបានរើសជនបរទេសចូលធ្វើការ ហើយពួកគេទាំងនោះពូកែៗខ្លាំងណាស់ ដូច្នេះយើងក៏បានទទួលជនបរទេសជំនាញជាក់លាក់ក្នុងពេលដំណាលគ្នានឹងការចាប់ផ្ដើមអាជីវកម្ម។ សម្រាប់អាជីវកម្មរបស់ក្រុមហ៊ុនយើង ដែលត្រូវការស្ដារឡើងវិញនូវដីមិនអំណោយផលនិងពង្រីកការផលិត ការរកបានធនធានមនុស្សពូកែៗ គឺជាភារកិច្ចបន្ទាន់។<br>② នៅពេលដំបូងៗ យើងបានបង់ថ្លៃគាំទ្រទៅឲ្យស្ថាប័នគាំទ្រដែលមានចុះឈ្មោះ ប៉ុន្តែដោយសារវាមានបន្ទុកថ្លៃចំណាយធំ យើងក៏បានប្ដូរមកជាការផ្ដល់ការគាំទ្រដោយក្រុមហ៊ុនយើងផ្ទាល់វិញ។ យើងពិបាករៀបចំឯកសារជាដើមមែន ប៉ុន្តែយើងអាចយកចំណែកនៃថ្លៃចំណាយនោះ មកបំពេញឲ្យការរើសបុគ្គលិកចូល ដូច្នេះយើងអាចពង្រីកការរើសចូលនូវជនបរទេសពូកែៗ ឲ្យកាន់តែច្រើនបន្ថែមទៀត។ ការធ្វើបែបនេះ បាន |

ជួយយ៉ាងច្រើនដល់ការពង្រីកអាជីវកម្មរបស់យើង។

【កិច្ចផ្តួចផ្តើមសម្រាប់ការរីកចម្រើនក្នុងអាជីព និង កិច្ចគាំទ្រដល់ការបង្កើនសមត្ថភាព】

(1) អំពីកិច្ចផ្តួចផ្តើមសម្រាប់ការរីកចម្រើនក្នុងអាជីព

① យើងផ្តល់ឱកាសសម្រាប់ការឡើងប្រាក់ឈ្នួលនិងការឡើងតំណែង ចំនួន2ដងក្នុងមួយឆ្នាំ តាមរយៈការវាយតម្លៃធនធានមនុស្សនិងការជួបជជែកផ្ទាល់ ដោយប្រើសន្លឹកប៉ាន់វាយតម្លៃខ្លឹមសារកិច្ចការដែលសាមីខ្លួនសរសេរដោយខ្លួនឯង ហើយយើងបង្ហាញផ្លូវសម្រាប់ការឡើងតំណែងជាអ្នកដឹកនាំក្រុមនីមួយៗ ដូចជាប្រធានវាលកសិកម្ម អ្នកគ្រប់គ្រងទីតាំងផ្ទាល់ និងអ្នកណែនាំជាដើម ដោយមិនគិតថាជាជនជាតិជប៉ុន ឬជនបរទេសទេ។

② មុននឹងជួបជជែកផ្ទាល់សម្រាប់ការវាយតម្លៃធនធានមនុស្ស ជាមួយអ្នកតំណាង ឬអ្នកគ្រប់គ្រងផ្នែកអាជីវកម្មផលិត យើងពិនិត្យថា តើខ្លឹមសារដែលមានសរសេរនៅក្នុងសន្លឹកវាយតម្លៃ ឆ្លុះបញ្ចាំងពីសមត្ថភាពពិតរបស់សាមីខ្លួនបានត្រឹមត្រូវដែរឬទេ ដោយជួបប្រជុំគ្នារវាងសមាជិកទាំងអស់នៃក្រុមផលិត និងបុគ្គលិកនៃការិយាល័យផែនការសាជីវកម្ម។

③ តំណែងអ្នកដឹកនាំក្រុមផលិតនៅពេលបច្ចុប្បន្ន ត្រូវបានកាប់រងដោយជនបរទេសជំនាញជាក់លាក់កម្រិត1 ដែលនៅធ្វើការតាំងពីអាជីវកម្មចាប់ផ្តើមដំបូង។

(2) កិច្ចផ្តួចផ្តើមនិងការគាំទ្រដល់ការបង្កើនសមត្ថភាព

① អ្នកដឹកនាំក្រុម ក៏ចូលរួមក្នុងការសង្កេតនៅដីផលិតជាដើមផងដែរ ដែលត្រូវរៀនបច្ចេកទេសពីអ្នកបំពេញការងារកសិកម្មនៅដីផលិតខ្នាតធំ។

② យើងបានផ្តួចផ្តើមឲ្យមានការគ្រប់គ្រងតួលេខជាដើម ដោយផ្តល់ជូននូវកុំព្យូទ័រ ហើយឲ្យបំពេញរបាយការណ៍ប្រចាំថ្ងៃសម្រាប់ការគ្រប់គ្រងឃ្លាំងនិងការក្តាប់បានពីវឌ្ឍនភាពការងារ និងរៀបចំផែនការផលិតប្រចាំឆ្នាំ ជាដើម។

③ យើងផ្តល់ការឧបត្ថម្ភថ្លៃចំណាយសម្រាប់ការរៀន 100% សម្រាប់ការយកបណ្ណបើកបររថយន្ត គ្រឿងចក្រធុនធ្ងន់ និងហ្វកលីហ្វ ជាដើម។ លើសពីនេះ យើងក៏ផ្តល់ប្រាក់ឈ្នួលសម្រាប់ពេលវេលារៀន ហើយជូនទៅកន្លែងរៀនជាដើម ដើម្បីមិនឲ្យមានបន្ទុកចំណាយសម្រាប់ការធ្វើដំណើរទៅរៀន។ នៅពេលបច្ចុប្បន្ននេះ មាន5នាក់ ក្នុងចំណោម6នាក់ ដែលយកបានបណ្ណបើកបរយានយន្តអ្វីម៉្យាង ដែល4នាក់មានបណ្ណបើកបរហ្វកលីហ្វ ហើយអ្នកមានបណ្ណបើកបរពិសេសធុនធំ បណ្ណបើកបរធុនមធ្យមបណ្ណបើកបរធម្មតា សុទ្ធតែមាន2នាក់។

④ យើងបានផ្តល់ការគាំទ្រផ្នែកឯកសារសម្រាប់ការប្រឡងជំនាញកម្រិត2។ ទោះជានៅមានចំណុចដែលត្រូវកែលម្អបន្ថែមទៀតសម្រាប់ការគាំទ្ររបស់ក្រុមហ៊ុនក៏ដោយ ប៉ុន្តែយើងបានជួយគាំទ្រក្នុងការព្រីនឯកសារនីតិវិធីប្រឡង និងសៀវភៅពុម្ពជាដើម ដោយសារតែខ្លឹមសាររបស់វាពិបាក ហើយបើប្រឡងមិនជាប់ នឹងបាត់បង់គុណសម្បត្តិស្នាក់នៅក្នុងប្រទេសជប៉ុន។ នៅពេលបច្ចុប្បន្ន មាន2នាក់ ដែលបានប្រឡងជាប់

ជំនាញកម្រិត2 ហើយពួកគេកំពុងជួយរុញច្រានអាជីវកម្មរបស់យើងឲ្យទៅមុខ។ ក្នុងនាមជាដៃគូពង្រីកអាជីវកម្មជាមួយគ្នា យើងពិតជាមានភាពរឹងមាំផ្នែកផ្លូវចិត្តខ្លាំងណាស់ ដែលពួកគេអាចនៅធ្វើការបានដោយគ្មានការកំណត់សុពលភាពស្នាក់នៅ ។

【កិច្ចសម្ភាសជាមួយធនធានមនុស្សមកពីបរទេស】




លោក លីអូ (យកបានជំនាញកម្រិត2)



ឆ្វេង៖ លោក ឡាន់ឌី (ជំនាញកម្រិត1 ប្រធានក្រុមផលិត)
ស្តាំ៖ លោក ហាន់ដុកុ (យកបានជំនាញកម្រិត2)

① ហេតុអ្វីបានជាអ្នកមកធ្វើការនៅប្រទេសជប៉ុន? តើអ្នកមានគម្រោងធ្វើការនៅប្រទេសជប៉ុនយូរប៉ុណ្ណា?

លីអូ៖ នៅប្រទេសរបស់ខ្ញុំ មិនសូវសម្បូរការងារធ្វើទេ ហើយប្រាក់ចំណូលក្នុងប្រទេសជប៉ុន ខ្ពស់ជាង ដូច្នេះខ្ញុំចង់រកប្រាក់បានច្រើនដើម្បីជួយគ្រួសារ។ ម្យ៉ាងទៀត ខ្ញុំក៏ចង់រៀនសូត្រពីវប្បធម៌ជប៉ុន និងរបៀបធ្វើការផងដែរ។ ខ្ញុំចង់នៅធ្វើការច្រើនឆ្នាំទៀត។

ហាន់ដុកុ៖ ព្រោះខ្ញុំគិតថា នៅប្រទេសជប៉ុន ខ្ញុំអាចរកប្រាក់បានច្រើនជាងនៅប្រទេសរបស់ខ្ញុំ។ ក្រៅពីនេះ ខ្ញុំក៏ចង់រៀនពីរបៀបធ្វើកសិកម្ម និងជាពិសេស គឺការដាំដុះដំឡូងជ្វា។ មកទល់ពេលនេះ ខ្ញុំមិនទាន់សម្រេចចិត្តថាត្រូវត្រលប់ទៅវិញនៅពេលណាទេ។ កាលពីឆ្នាំមុន

ខ្ញុំបានប្រឡងជាប់ជំនាញកម្រិត2។

ឡាន់ឌី៖ ហេតុផលគឺដោយសារ ប្រាក់ចំណូលខ្ពស់ និងចង់រៀនពីបច្ចេកទេសកសិកម្ម។ ខ្ញុំបានមកប្រទេសជប៉ុនក្នុងឆ្នាំ2016 និងបានធ្វើការនៅវាលកសិកម្មផ្សេងមួយទៀតក្នុងនាមជាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ហើយបន្ទាប់ពីនោះ ខ្ញុំបានប្រឡងជាប់ជំនាញជាក់លាក់កម្រិត1។ ឆ្នាំក្រោយ ខ្ញុំនឹងប្រឡងយកជំនាញកម្រិត2។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងអាចហៅគ្រួសាររបស់ខ្ញុំមករស់នៅប្រទេសជប៉ុនបានក្នុងពេលអនាគត។

② សូមរៀបរាប់អំពីខ្លឹមសារការងាររបស់អ្នក។

លីអ៊ូ៖ ខ្ញុំធ្វើការជាអ្នកដឹកនាំបុគ្គលិកក្រៅម៉ោង សម្រាប់ការងាររើសផ្លែ។ ខ្ញុំរៀបចំកាលវិភាគការងារប្រចាំថ្ងៃ ថាត្រូវយកដំឡូងប្រភេទណា ចំនួនប៉ុន្មានប្រអប់ បញ្ជូនទំនិញទៅណា ត្រឹមម៉ោងប៉ុន្មាន ជាដើម និងគ្រប់គ្រងដំណើរការទាំងមូលដើម្បីធានាឲ្យបានដូចការកុម្ម៉ង់ ដោយចាំបញ្ជានៅទីតាំងផ្ទាល់។

ឡាន់ឌី៖ ខ្ញុំធ្វើទាំងអស់ តាំងពីបណ្ដុះសំណាបដំឡូងផ្កា រហូតដល់ធ្វើចម្ការ និងប្រមូលផល។

ហាន់ដុកុ៖ ខ្លឹមសារការងាររបស់ខ្ញុំ ដូចគ្នានឹងឡាន់ឌីដែរ។ ពួកយើងធ្វើជាមួយគ្នា។

③ តើកន្លែងធ្វើការរបស់អ្នក មានបរិយាកាសងាយស្រួលធ្វើការងារដែរឬទេ? តើចំណុចណាដែលអ្នកគិតថាការងាររបស់អ្នកមានន័យ?

ឡាន់ឌី៖ ងាយស្រួលធ្វើការងារណាស់។ នៅទីនេះ មានបរិយាកាសខិតខំធ្វើជាមួយគ្នា

ដោយមិនប្រកាន់ជាតិសាសន៍ ហើយខ្ញុំពិតជាត្រេកអរមែនទែន។ នៅពេលនេះ ខ្ញុំគឺជាអ្នកដឹកនាំផ្នែកផលិត ហើយខ្ញុំពិតជាមានអារម្មណ៍ចង់ធ្វើនៅពេលដែលមើលឃើញផ្លូវទៅមុខក្នុងអាជីព។

ហាន់ដុកុះ ងាយស្រួលធ្វើការងារណាស់ ដោយសារគេទុកចិត្តឲ្យខ្ញុំធ្វើការងារផ្សេងៗ ហើយមានអារម្មណ៍ថា យើងខិតខំធ្វើជាមួយគ្នាដូចជាដៃគូ។ មិនមានការកំណត់តួនាទី ឬខ្លឹមសារការងារ ដោយបែងចែកតាមជាតិសាសន៍ទេ។

④ តើការប្រាស្រ័យទាក់ទងគ្នានៅកន្លែងធ្វើការ មានភាពរលូនដែរឬទេ? តើមានចំណុចណាដែលអ្នកលៃលកសម្របសម្រួលដែរឬទេ?

លីអូះ ចំពោះការងារនៅកន្លែងរើសផ្លែ មានបុគ្គលិកក្រៅម៉ោងជនជាតិជប៉ុនចំនួន20នាក់ ហើយខ្ញុំពិភាក្សាជាមួយអ្នកដែលមានតួនាទីមើលការ និងឲ្យគាត់ប្រាប់បន្តពីការបញ្ជាការងារទៅអ្នកទាំងអស់គ្នា។ ហើយមិនមែនត្រឹមតែនិយាយប្រាប់ទេ ខ្ញុំក៏នាំធ្វើផងដែរ ដែលនាំឲ្យអ្នកទាំងអស់គ្នាធ្វើតាម។

⑤ នៅក្នុងការងារ តើមានរឿងអ្វីដែលអ្នកប្រុងប្រយ័ត្នជាពិសេសដែរឬទេ ទាក់ទងនឹងសុវត្ថិភាពនិងអនាម័យ?

លីអូះ នៅពេលធ្វើការងារផ្ទុកឡើងនូវប្រអប់ដាក់សម្រាប់បញ្ជូនទំនិញ ដោយប្រើលីហ្វ យើងពិតជាប្រុងប្រយ័ត្នមែនទែន ដោយសារត្រូវឆ្លងកាត់ចំហៀងមនុស្សច្រើនដែលកំពុងធ្វើការងារ។ ប្រអប់ដាក់នីមួយៗ មានទម្ងន់ចាប់ពី20kgឡើងទៅ ហើយយើងត្រូវផ្ទុកឡើង

នូវប៉ាឡែតដោយរៀបជា3ឬ4ថ្នាក់ ដោយប៉ាឡែតនីមួយៗមានប្រអប់ដាក់ចំនួន24។ យើងប្រុងប្រយ័ត្នយ៉ាងណាមិនឲ្យមានគ្រោះថ្នាក់ ព្រោះយើងត្រូវធ្វើប្រតិបត្តិការលីហ្វជាច្រើនគ្រឿងក្នុងពេលដំណាលគ្នា។

ឡាន់ឌី៖ នៅពេលដឹកជញ្ជូនពេលប្រមូលផល ខ្ញុំបើកបរដោយប្រុងប្រយ័ត្នជាពិសេស។

ហាន់ដុកុ៖ ខ្ញុំប្រុងប្រយ័ត្នចំពោះការចាត់ចែងគ្រឿងចក្រ និងរបៀបបាញ់ថ្នាំកសិកម្ម ហើយចាប់ពីឆ្នាំមុនមក យើងប្រើដ្រូនសម្រាប់ការបាញ់ថ្នាំ។

⑥ ចុះកន្លែងនៅ និងទំនាក់ទំនងជាមួយអ្នកនៅក្នុងមូលដ្ឋានវិញ មានលក្ខណៈយ៉ាងណាដែរ?

លីអ្វូ៖ កន្លែងដែលខ្ញុំស្នាក់នៅ នៅក្បែរគ្នានឹងកន្លែងរើសផ្លែ ជិះកង់តែ3នាទីទេ ហើយវាពិតជាល្អសម្រាប់ខ្ញុំណាស់។

មិត្តភក្តិរបស់ខ្ញុំ បានបបួលខ្ញុំទៅលេងបាល់ទះនៅសាលកីឡាក្នុងមូលដ្ឋានរបស់ខ្ញុំ។

ឡាន់ឌី៖ ខ្ញុំរស់នៅកន្លែងដូចគ្នានឹងលីអ្វូដែរ។ ក្នុងមួយបន្ទប់មាន2នាក់ ហើយមានបន្ទប់ផ្ទាល់ខ្លួនរៀងៗខ្លួន។ មិនមានកន្លែងណាដែលមានអារម្មណ៍ថាមិនស្រណុកទេ។ ខ្ញុំក៏ទៅលេងបាល់ទះជាមួយលីអ្វូដែរ។ នៅទីនោះ យើងជុំគ្នាលេងសប្បាយទាំងអស់គ្នា ទាំងជនបរទេស និងជនជាតិជប៉ុន។

⑦ តើអ្នកបានរៀនសម្រាប់ការប្រឡងជំនាញកម្រិត2 ដូចម្តេចខ្លះ?

លីអ្វូ៖ ខ្ញុំមិនពូកែមើលសៀវភៅរៀនទេ ប៉ុន្តែមុនប្រឡងប្រហែលមួយខែ ខ្ញុំបានរៀនដោយ

មើល YouTube និងមើលសៀវភៅពុម្ពនិងកម្រងសំណួរ តាមទូរសព្ទនិងកុំព្យូទ័រ។ ចំពោះភាសាជប៉ុន មានអ្នកស្ម័គ្រចិត្តបង្រៀន នៅសាលសាធារណៈសហគមន៍ ហើយគាត់ថែមទាំងបានរៀបចំសៀវភៅសម្រាប់ការប្រឡងភាសាជប៉ុនទៀតផង។

ហាន់ដុកុ៖ ខ្ញុំរៀនដោយអានសៀវភៅពុម្ពនៅលើគេហទំព័រ និងមើល YouTube។ នៅលើ YouTube មានការបង្រៀនផ្សាយផ្ទាល់ ហើយគេបង្រៀនសង្ខេបទៅតាមចំណុចៗ ដូច្នេះវាងាយរៀនខ្លាំងណាស់។ ខ្ញុំក៏បានទៅរៀនភាសាជប៉ុននៅសាលសាធារណៈផងដែរ។ ខ្ញុំពិតជាកោតសរសើរជនជាតិជប៉ុនខ្លាំងណាស់ ដែលមានអ្នកស្ម័គ្រចិត្តបង្រៀនបែបនេះ។

⑧ តើអ្នកមានគោលដៅអ្វីក្នុងពេលអនាគត? តើអ្នកគិតយ៉ាងណាចំពោះអនាគតនៅក្នុងប្រទេសកំណើតរបស់អ្នក?

លីអូ៖ មិនដឹងថាប៉ុន្មានឆ្នាំក្រោយពីនេះទេ ប៉ុន្តែនៅពេលត្រលប់ទៅប្រទេសកំណើតវិញ ខ្ញុំចង់បង្កើតចម្ការដូងប្រេង។

ហាន់ដុកុ៖ ខ្ញុំមិនគិតថាចង់ត្រលប់ទៅវិញភ្លាមៗទេ ប៉ុន្តែខ្ញុំចង់បើកហាងផ្ទាល់ខ្លួន គឺហាងដែលដូចនឹងផ្សារលក់ទំនិញក្នុងប្រទេសជប៉ុនដែរ។

ឡាន់ឌី៖ ប្រពន្ធរបស់ខ្ញុំ ចូលចិត្តធ្វើម្ហូប ដូច្នេះខ្ញុំចង់បើកហាងកាហ្វេជាដើម ពីរនាក់។